Australian Government

Inspector-General of Taxation

Taxation Ombudsman

# តើមានពាក្យបណ្ដឹងតវ៉ា អំពីពន្ធដារឬ?



Khmer

# តើយើងខ្ញុំជានរណា

អគ្គអធិការ និងមន្ត្រីទទួលបណ្តឹងតវ៉ាពលរដ្ឋអំពីពន្ធដារ (Inspector-General & Taxation Ombudsman - IGTO) គឺជាទីភ្នាក់ងាររដ្ឋាភិបាលសហព័ន្ធឯករាជ្យដែលទទួលខុសត្រូវដើម្បីជួយអ្នកពីពាក្យបណ្តឹងរបស់អ្នក អំពីសកម្មភាពរដ្ឋបាលរបស់ក្រសួងពន្ធដារអូស្ត្រាលី (Australian Taxation Office - ATO) និងក្រុមប្រឹក្សាអ្នកអនុវត្តពន្ធដារ (Tax Practitioners Board - TPB)។



1300 44 88 29
(ថ្លៃហៅទូរស័ព្ទដូចក្នុងតំបន់)

# របៀបដែលយើងខ្ញុំអាចជួយអ្នក

យើងខ្ញុំផ្តល់ជូនសេវាកម្មឯកទេសពន្ធដារ ដែលឯករាជ្យ ហើយឥតគិតថ្លៃដើម្បីជួយ អ្នកដោះស្រាយពាក្យបណ្តឹងរបស់អ្នក។

'សកម្មភាពរដ្ឋបាល' គឺជាពាក្យទូលំទូលាយ ដែលជាទូទៅ គ្របដណ្តប់លើ ភាពយុត្តិធម៌ និងភាពសមហេតុផលនៃការទាក់ទង ឬអន្តរកម្មរបស់ ATO ឬ TPB ជាមួយអ្នក។

ជាឧទាហរណ៍ខ្លះៗកន្លែងដែល IGTO អាចជួយអ្នក រួមបញ្ចូលទាំង ក៏ប៉ុន្តែ មិនកំណត់ចំពោះ៖

- ពេលវេលាឆ្លើយតបទៅនឹងសំណើរបស់អ្នក
- ចរិយាមាយាទរបស់មន្ត្រី ATO ឬ TPB
- ភាពអាចរកបាននៃសេវាកម្មតាមអនឡាញ

www.igt.gov.au

- ការធានាឬភាព ឬភាពគ្រប់គ្រាន់នៃការពន្យល់ពីសកម្មភាពធ្វើឡើងដោយ ATO ឬ TPB
- ធានាថាសកម្មភាពរបស់ ATO ឬ TPB ស្របតាមគោលនយោបាយ និងនីតិវិធីរបស់ពួកគេ ហើយ
- ធានាថា ATO ឬ TPB ទាក់ទងជាមួយអ្នកក្នុងបែបបទយុត្តិធម៌ និងមានតម្លាភាព ហើយពិចារណាពីព័ត៌មានពាក់ព័ន្ធទាំងអស់ដែលបាន ផ្តល់ រួមទាំងការធ្វើសវនកម្ម និងការស៊ើបអង្កេត។

ប្រសិនបើអ្នកមិនប្រាកដថាយើងខ្ញុំអាចជួយអ្នកបានទេ សូមទាក់ទងមកយើងខ្ញុំ។

ប្រសិនបើយើងខ្ញុំមិនអាចជួយអ្នកដោយផ្ទាល់បានទេ យើងខ្ញុំនឹងប្រឹងប្រែងឱ្យអស់ពីសមត្ថភាព ដើម្បីផ្តល់ដំបូន្មានដល់ភ្នាក់ងារ ឬអង្គភាពដែលសមរម្យបំផុតដើម្បីជួយអ្នក។

GPO Box 551, Sydney NSW 2001

# ដំណើរការដាក់ពាក្យបណ្ដឹង

ដើម្បីដាក់ពាក្យបណ្ដឹងរបស់អ្នក ជាមួយការិយាល័យរបស់យើងខ្ញុំ សូមមើលផ្នែក "របៀបទាក់ទងមកយើងខ្ញុំ" (How to contact us)។

បន្ទាប់ពីអ្នកដាក់ពាក្យបណ្ដឹងហើយ មន្ត្រីស៊ើបអង្កេត IGTO នឹងទាក់ទងអ្នកក្នុងរយៈពេលពីរថ្ងៃនៃថ្ងៃធ្វើការ ដើម្បីទទួលស្គាល់ ហើយពិភាក្សាអំពីបណ្ដឹងរបស់អ្នកជាមួយអ្នក។

យើងខ្ញុំនឹងជួយអ្នកដោយផ្ទាល់ ដើម្បីដោះស្រាយពាក្យបណ្ដឹងរបស់អ្នក ប្រសិនបើអាចធ្វើទៅបាន។

យើងខ្ញុំអាចត្រូវការព័ត៌មានបន្ថែមពីអ្នក ពី ATO ឬ TPB ដើម្បីឱ្យកាន់តែយល់ដឹងច្បាស់អំពីពាក្យបណ្ដឹងរបស់អ្នក និងដើម្បីកំណត់ពីរបៀបដែលយើងខ្ញុំអាចជួយអ្នកបានល្អបំផុត។

យើងខ្ញុំនឹងរក្សាអ្នកឱ្យបានទាន់បច្ចុប្បន្នភាព ទាក់ទងនឹងវឌ្ឍនភាពរបស់យើងហើយផ្ដល់ឱ្យអ្នកនូវពេលវេលានៃការស៊ើបអង្កេតរបស់យើងខ្ញុំពេញទូទាំងដំណើរការ។

# របៀបទាក់ទងមកយើងខ្ញុំ

www.igt.gov.au

**1300 44 88 29**
(ថ្លៃហៅទូរស័ព្ទដូចក្នុងតំបន់)

**GPO Box 551**
**Sydney NSW 2001**

ប្រសិនបើអ្នកចង់ដាក់ពាក្យបណ្ដឹងជាភាសាផ្សេងក្រៅពីភាសាអង់គ្លេស សូមហៅទូរស័ព្ទទៅ សេវាកម្មបកប្រែភាសាសរសេរ និងនិយាយ (Translating and Interpreting Service - TIS) លេខ **131 450**។

ប្រសិនបើអ្នកមានបញ្ហាក្នុងការស្ដាប់ ឬនិយាយ ហើយមានលទ្ធភាពប្រើប្រាស់ឧបករណ៍ទូរអង្គុលីលេខ (TTY) ឬឧបករណ៍ម៉ូដឹមដែលសមស្រប សូមទូរស័ព្ទលេខ **13 36 77**។

ប្រសិនបើអ្នកមិនមានលទ្ធភាពប្រើប្រាស់ឧបករណ៍ TTY ឬឧបករណ៍ម៉ូដឹម បានទេ សូមទូរស័ព្ទ សេវាកម្មបញ្ជូនបន្តពាក្យសម្ដី (Speech to Speech Relay Service) លេខ **1300 555 727**។